ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

**ធនាគារជាតិ នៃ កម្ពុជា**

លេខ.........................................................

# មតិស្វាគមន៍
# លោកជំទាវ ជា សិរី ទេសាភិបាល ធនាគារជាតិនៃកម្ពុជា
# ក្នុងកម្មវិធីសម្ពោធសៀវភៅ "អនុស្សាវរីយ៍ និងគំនិតអណ្តែតត្រសែត ឆ្នាំ១៩៥១ - ឆ្នាំ២០២៣"

**ថ្ងៃព្រហស្បតិ៍ ៣រោច ខែស្រាពណ៍ ឆ្នាំរោង ឆស័ក ព.ស.២៥៦៨**
**ត្រូវនឹងថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៤ នៅសណ្ឋាគារហៃយ៉ាត់ រីជិនស៊ី ភ្នំពេញ**

- **សូមថ្វាយបង្គំ សម្តេចក្រុមព្រះ នរោត្តម ចក្រពង្ស ឧត្តមក្រុមប្រឹក្សាផ្ទាល់ ព្រះមហាក្សត្រ**
- **សូមគោរព ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ទាំងអស់ ជាទីមេត្រី!**

ថ្ងៃនេះ ខ្ញុំម្ចាស់នាងខ្ញុំមានសេចក្តីសោមនស្សរីករាយក្រៃលែងដែលបានចូលរួម ក្នុងពិធីសម្ពោធសៀវភៅ "អនុស្សាវរីយ៍ និងគំនិតអណ្តែតត្រសែត ឆ្នាំ១៩៥១ - ឆ្នាំ២០២៣" នាពេលនេះ។ ពិធីនេះ រៀបចំឡើងក្នុងគោលបំណង សម្ពោធនូវសៀវភៅដែលបានរៀបរាប់អំពីដំណើរជីវិតរបស់ ឯកឧត្តម ជា ចាន់តូ ទេសាភិបាលកិត្តិយស ធនាគារជាតិនៃកម្ពុជា និងព្រឹត្តិការណ៍នានាដែលមានតម្លៃជាប្រវត្តិសាស្ត្រក្នុងរយៈពេលប៉ុន្មានទសវត្សរ៍ចុងក្រោយនេះ ដែលឯកឧត្តមបានឆ្លងកាត់ដោយផ្ទាល់។

ក្នុងឱកាសនេះ ខ្ញុំម្ចាស់នាងខ្ញុំសូមគោរពថ្លែងអំណរព្រះគុណ សម្តេចក្រុមព្រះ ដែលបានឆ្លៀតពេលវេលាដ៏មមាញឹកផ្តល់កិត្តិយសយាងចូលរួមក្នុងពិធីនេះ និងសូមថ្លែងអំណរគុណចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ទាំងអស់ ដែលបានចំណាយពេលវេលាដ៏មានតម្លៃអញ្ជើញចូលរួមក្នុងកម្មវិធីនាព្រឹកនេះ។

**សម្តេចក្រុមព្រះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីគោរព និងជាមេត្រី!**

ខ្ញុំម្ចាស់នាងខ្ញុំ សូមចាត់ទុកសៀវភៅ "អនុស្សាវរីយ៍ និងគំនិតអណ្តែតត្រសែត ឆ្នាំ១៩៥១-ឆ្នាំ២០២៣" នេះ ជាឯកសារដ៏មានសារៈសំខាន់មួយសម្រាប់សង្គមជាតិ និងយុវជនដែលជាអ្នកបន្តវេនជំនាន់ក្រោយ



ប្រអប់សំបុត្រលេខ ២៥, ឡូត៍លេខ ៤៨ ផ្លូវលេខ ១០២ កែងនឹងផ្លូវលេខ ១៩ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ , ទូរស័ព្ទ : (៨៥៥-២៣) ៧២២ ៥៦៣, ទូរស័ព្ទ / ទូរសារ : (៨៥៥-២៣) ៤២៦ ១១៧

ដើម្បីបានសិក្សាស្វែងយល់ និងអភិវឌ្ឍសមត្ថភាពរបស់ខ្លួន ក្នុងការបន្តរួមចំណែកអភិវឌ្ឍសេដ្ឋកិច្ចសង្គមជាតិ ទាំងបច្ចុប្បន្ន និងអនាគតឱ្យកាន់តែមានភាពរីកចម្រើនថែមទៀត។

សៀវភៅនេះ គឺជាសម្មតិកម្មដែលបានរៀបរាប់អំពីដំណើរជីវិត បទពិសោធន៍ ព្រឹត្តិការណ៍ជាច្រើន ដែល ឯកឧត្តម ទេសាភិបាលកិត្តិយស បានឆ្លងកាត់តាំងពីកុមារភាព ព្រមទាំងបានឆ្លុះបញ្ចាំងអំពីដំណើរការដឹកនាំ និងការចូលរួមយ៉ាងសកម្មក្នុងការកសាង និងអភិវឌ្ឍសេដ្ឋកិច្ចជាតិ ផ្តើមចេញពីសេដ្ឋកិច្ចផែនការ រហូតដល់ការគ្រប់គ្រងរូបិយវត្ថុ ការត្រួតពិនិត្យគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ ដំណើរការពិលាសនៃសេដ្ឋកិច្ចក្នុងក្របខ័ណ្ឌនយោបាយខុសៗគ្នា ជាពិសេសការកសាងប្រទេសចាប់ផ្តើមពីបាតដៃទទេ ក្រោយការដួលរលំនៃរបបប៉ុលពតរហូតដល់មានការរីកចម្រើនដូចពេលបច្ចុប្បន្ន។ ដើម្បីជ្រាបលម្អិតអំពីសៀវភៅនេះ លោក Jean-Deniel Gardere ទីប្រឹក្សាធនាគារជាតិនៃកម្ពុជា នឹងធ្វើការបកស្រាយក្នុងពេលបន្តិចទៀតនេះ។

**សម្តេចក្រុមព្រះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញា ជាទីគោរព និងជាមេត្រី!**

ឆ្លៀតក្នុងឱកាសនេះ នាងខ្ញុំក៏សូមថ្លែងអំណរគុណចំពោះ ឯកឧត្តម ជា ចាន់តូ ទេសាភិបាលកិត្តិយស ដែលបានចែករំលែកនូវរឿងរ៉ាវ ក៏ដូចជាបទពិសោធន៍ និងស្នាដៃការងារល្អៗជាច្រើនរបស់ឯកឧត្តម និង សូមអរគុណចំពោះក្រុមការងារ ព្រមទាំងសហការីទាំងអស់ដែលបានខិតខំប្រឹងប្រែងក្នុងការជំរុញការងារនេះ ឱ្យសម្រេចបានដោយជោគជ័យ។

ជាថ្មីម្តងទៀត ខ្ញុំម្ចាស់នាងខ្ញុំសូមថ្លែងអំណរព្រះគុណ សម្តេចក្រុមព្រះ និងថ្លែងអំណរគុណ ចំពោះ ឯកឧត្តម លោកជំទាវ លោក លោកស្រី នាងកញ្ញាទាំងអស់ ដែលមានវត្តមានក្នុងកម្មវិធីថ្ងៃនេះ។

ជាទីបញ្ចប់ ខ្ញុំម្ចាស់នាងខ្ញុំសូមថ្វាយព្រះពរ សម្តេចក្រុមព្រះ និងសូមជូនពរ ឯកឧត្តម លោកជំទាវ លោកលោកស្រី នាងកញ្ញា ជួបប្រទះតែពុទ្ធពរទាំងបួនប្រការគឺអាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

**សូមអរគុណ!**